**តុលាការខេត្តកំពង់ធំ**

សាលក្រម

លេខ ៣០ "ក" ចុះថ្ងៃទី ១១

ខែ កក្កដា ឆ្នាំ ២០០៥

សំណុំរឿង

លេខ ៨២ ចុះថ្ងៃទី ០៨

ខែ មិថុនា ឆ្នាំ ២០០៥

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

### នាមនាមប្រជារាស្ត្រខ្មែរ

តុលាការខេត្តកំពង់ធំ បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាព របស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តកំពង់ធំ ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៥ ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជំរះ**

លោក [redacted]

**តំណាងអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជំរះរឿងក្តីរដ្ឋប្បវេណីលេខ ៨២ ចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្រពន្ធ ។

-រវាងដើមចោទ ម ឆ ហៅ ៥ អាយុ ៣៣ឆ្នាំ របររកស៊ីបើកបរតាក់ស៊ី នៅផ្ទះលេខ ១៩អឺសេរ៉ូ ផ្លូវលេខ ៨១ សង្កាត់ផ្សារថ្មី២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ឪពុកឈ្មោះ ម គ "ស" ម្តាយឈ្មោះ ម ស "វ" ប្រពន្ធឈ្មោះ ស ណអ កូនគ្មាន ដែលមានមេធាវីលោក ឈិត សារិទ្ធិ ។

-និង ចុងចម្លើយឈ្មោះ ស ណអ ភេទស្រី អាយុ ២៤ឆ្នាំ របររកស៊ីគ្រូបង្រៀន នៅភូមិត្រស់ ឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ឪពុកឈ្មោះ ឌ ស "វ" ម្តាយឈ្មោះ ភ គស "វ" ប្តីឈ្មោះ ម ឆ កូនគ្មាន ។

### ដំណើររឿងហេតុមានដូចតទៅ

តាមពាក្យបណ្តឹងចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៥ របស់ដើមចោទឈ្មោះ ម ឆ បានប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្រពន្ធឈ្មោះ ស ណអ ដោយមូលហេតុថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយនាង ស ណអ ត្រឹមត្រូវតាមប្រពៃណីកាលពីថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៥ ។ បន្ទាប់ពីបានរៀបការរួចមកបានសេចក្តីសុខជាមួយគ្នាជាធម្មតាទេ បានរយៈពេល ០៥ខែជាង ទើបបានមានទំនាស់ដោយការរកស៊ីប្រពន្ធមិនទុកចិត្ត... ជាប្តីពីបញ្ហារឿងលុយកាក់ក៏ចេះតែមានទំនាស់រកាំរកូសរហូតដល់ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៥ ខ្លួនជាមួយប្រពន្ធក៏បានព្រមព្រៀងឯកភាពលែងលះគ្នា ...បាន

*សាលក្រមនេះចូលស្ថាពរចាប់តាំងពីថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៥ តទៅ*
*ដោយគូក្តីមិនចូលតវ៉ាតាមកំណត់ច្បាប់ ។*
*កំពង់ធំ, ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៥*
**ប្រធានតុលាការខេត្ត**
[redacted]

រកអនាគតថ្មីរៀងៗខ្លួន ទើបបានប្តឹងមកតុលាការនេះ ។ ដូច្នេះខ្លួនប្តឹងសុំអោយបានដាច់សមគ្គសង្វាសពីគ្នាតាមច្បាប់តទៅ ដោយអស់មនោសញ្ចេតនានឹងគ្នាជាប្តីប្រពន្ធតទៅទៀតហើយ ។ កូនគ្មានទេ ។ ទ្រព្យសម្បត្តិដើមរបស់ខ្លួនគ្មានទេ ។ ចំណែកឯទ្រព្យសម្បត្តិរួមក៏គ្មានដែរ ។

-បានឃើញរបាយការណ៍ជូនរឿងទៅជំនុំជំរះលេខ ៣៩២ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៥ ។

-បានឃើញដីកាចាត់តាំងចៅក្រមលេខ ៣៩៣ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៥ ។

## នាពេលសវនាការ

-ដើមចោទឈ្មោះ ម ន ឆ្លើយថា ខ្លួនរៀបអាពាហ៍ពិពាហ៍ជាមួយនាង ស ណរះ ជាប្តីប្រពន្ធនឹងគ្នាត្រឹមត្រូវតាមច្បាប់កាលពីថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៥ បានចុះសំបុត្រអាពាហ៍ពិពាហ៍នៅមន្ត្រីអត្រានុកូលដ្ឋានឃុំបល្ល័ង្គ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ។ ការនៅរួមរស់ជាមួយគ្នាមិនបានសេចក្តីសុខគ្មានទំនុកចិត្តគ្នាទៅវិញទៅមករកាំរកូសជាប្រចាំពីរឿងមុខរបររកស៊ី ហើយទ្រព្យសម្បត្តិដើម និងទ្រព្យសម្បត្តិរួមគ្មានទេ ។ ខ្លួនអស់មនោសញ្ចេតនា និង រួមរស់នៅជាមួយប្រពន្ធឈ្មោះ ស ណរះ តទៅទៀតហើយ សុំអោយដាច់សមគ្គសង្វាសពីគ្នាតាមច្បាប់ ។

-ចុងចម្លើយឈ្មោះ ស ណរះ ឆ្លើយថា ខ្លួនពិតជាបានរៀបអាពាហ៍ពិពាហ៍ជាមួយដើមចោទត្រឹមត្រូវតាមច្បាប់ប្រាកដមែន ។ ទ្រព្យសម្បត្តិដើម ទ្រព្យសម្បត្តិរួម និង កូនគ្មានទេ រួមរស់នៅជាមួយគ្នាលំបាកវេទនាណាស់ ដូចនៅក្នុងគុកឥតជញ្ជាំងប្តីគ្មានស្មោះត្រង់ដូចជា គណនេយ្យបញ្ញើប្រាក់នៅធនាគារអាស៊ីក៏ប្តីមិនព្រមដាក់ឈ្មោះខ្លួនជាមួយក្នុងការបើកគណនេយ្យបើកប្រាក់បញ្ញើនោះដែរ រហូតប្រច័ណ្ឌខ្លួនធ្វើអោយយើងទាំង ០២នាក់មិនអាចចុះសំរុងគ្នាបាន សុំឯកភាពអោយបានដាច់សមគ្គសង្វាសពីគ្នាតាមច្បាប់តទៅ ។

## តំណាងអយ្យការសន្និដ្ឋានថា :

ចំពោះរឿងក្តីនេះអយ្យការស្នើសុំតុលាការសំរេចតាមច្បាប់ ។

-ក្រោយពីបានស្តាប់ដើមចោទអោយការណ៍ និង ប្តឹងសុំ

-ក្រោយពីបានស្តាប់ចម្លើយចុងចម្លើយ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់ហើយ

## តុលាការ

-យល់ឃើញថា : ពាក្យបណ្តឹងចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៥ របស់ដើមចោទឈ្មោះ ម ន មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-យល់ឃើញថា : ដើមចោទឈ្មោះ ម ន បានប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្តីឈ្មោះ ស ណរះ ដោយសំអាងហេតុថា ខ្លួនបានរៀបការជាមួយចុងចម្លើយជាប្តីប្រពន្ធនឹងគ្នាតាំងពីថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៥ រួមរស់នៅជាមួយគ្នាគ្មានកូនទេ ហើយមិនចុះសំរុងដោយប្រពន្ធមិនទុកចិត្តខ្លួនពីរឿងលុយកាក់រកស៊ីទើបមានទំនាស់រកាំរកូសរហូតមក ។

-យល់ឃើញថា : មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ដើមចោទ និង ចុងចម្លើយពិតជាបានរៀបអាពាហ៍

ពិពាហ៍ជាប្តីប្រពន្ធនឹងគ្នាត្រឹមត្រូវតាមច្បាប់ពីថ្ងៃទី ០១ ខែ កុម្ភ. ឆ្នាំ ២០០៥ ហើយស្ម័គ្រចិត្តលែងលះដោយអស់មនោសញ្ចេតនានឹងគ្នាប្រាកដមែន ។

-យល់ឃើញថា : ទ្រព្យសម្បត្តិដើម និង ទ្រព្យសម្បត្តិរួមរបស់គូភាគីគ្មានទេ ។ ចំណែកឯកូនក៏គ្មានដែរ ។

-យល់ឃើញថា : គូភាគីមិនអាចរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធតទៅទៀតបានទេ អស់មនោសញ្ចេតនានឹងគ្នាហើយ ។ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ។

**ហេតុដូច្នេះតុលាការខេត្តកំពង់ធំ**

**វិនិច្ឆ័យសេចក្តី**

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី ០៨ ខែ មិថុនា ឆ្នាំ ២០០៥ របស់ដើមចោទឈ្មោះ ម ន ហៅ ៨ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-សំរេចឱ្យដើមចោទឈ្មោះ ម ន ហៅ ៨ និង ចុងចម្លើយឈ្មោះ ស ណអ ដាច់សមគ្គសង្វាសពីគ្នាតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ចាប់ពីសាលក្រមនេះមានអានុភាពអនុវត្តតទៅ ។

៣-ឱ្យឈ្មោះនាង ស ណអ ស្ថិតនៅក្នុងភាពមេម៉ាយចំនួន ៣០០ថ្ងៃគិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តីពន្ធហ្វឹង ១.៨០០រ៛០០ រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ ២០០រ៛០០ រង្វាន់ប្រគល់ដីកាកោះ ៩.០០០រ៛០០ សរុប ១.០០០រ៛០០ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រ៛០០ ដែលដើមចោទបានបង់រួចហើយ ។

៥-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី និង មេធាវី បើភាគីណាមិនសុខចិត្តមានសិទ្ធិប្តឹងឧទ្ធរណ៍ ក្នុងរយៈពេល ០២ខែតាមកំណត់ច្បាប់ ។

**ចៅក្រមជំនុំជំរះ**

**ហត្ថលេខា និង ត្រា**

[redacted]

**បានឃើញ**

**ប្រធានតុលាការខេត្ត**

[redacted]